# កិច្ចការបញ្ចប់មេរៀនទី៥-ពាក្យចួន

**អំណាន:** ចូរសូត្រមេសូត្រខាងក្រោម រួចឆ្លើយនឹងសំណួរ ។

" អនាម័យនាំមកនូវសុខភាព "

ប្រដាប់ប្រដា សម្រាប់សិក្សា មានច្រើនអនេក
ក្ដារបិកសៀវភៅ កាតាបល្អប្លែក បន្ទាត់ជ័រដែក
ប្រើគួសសរសេរ ។
ជ័រលុបខ្មៅដៃ ទុកប្រើរាល់ថ្ងៃ សប្បាយម្ល៉េះទេ
ខិតខំសូត្ររៀន មិនចម្លងគេ កុំនៅទំនេរ
ទើបមានប្រយោជន៍ ។

គូសសញ្ញា ✓ ក្នុងប្រអប់ ☐ ចម្លើយមួយដែលត្រឹមត្រូវ ។

១. តើតើមេសូត្រខាងលើនិយាយពីអ្វី ?

☐ ក. ការខិតខំរៀនសូត្រ ☐ ខ. សម្ភារៈសិក្សា
☐ គ. ការគោរពទង់ជាតិ ☐ ឃ. ការចូលរៀន

២. តើមេសូត្រខាងលើក្នុងមួយវគ្គ មានប៉ុន្មានឃ្លា ?

☐ ក.ប្រាំពីរឃ្លា ☐ ខ. បីឃ្លា
☐ គ. បួនឃ្លា ☐ ឃ. ប្រាំមួយឃ្លា

៣. តើឃ្លានីមួយៗ មានប៉ុន្មានព្យាង្គ ?

☐ ក. បីព្យាង្គ ☐ ខ. បួនព្យាង្គ
☐ គ. ប្រាំព្យាង្គ ☐ ឃ. ប្រាំពីរព្យាង្គ

៤. តើពាក្យ "ប្រដា" ក្នុងល្បះទីមួយ ចួននឹងពាក្យអ្វី ?

☐ ក. ប្លែក ☐ ខ. សៀវភៅ
☐ គ. សម្រាប់ ☐ ឃ. សិក្សា

៥. តើពាក្យ "អនេក" ក្នុងល្បះទីមួយ ចួននឹងពាក្យអ្វី ?

☐ ក. ប្លែក ☐ ខ. សៀវភៅ
☐ គ. សម្រាប់ ☐ ឃ. សិក្សា

៦. តើមេសូត្រខាងលើមានប៉ុន្មានវគ្គ ។

☐ ក. ពីរវគ្គ ☐ ខ. បីវគ្គ
☐ គ. បួនវគ្គ ☐ ឃ. ប្រាំវគ្គ

LIVEWORKSHEETS

## សំណេរ

១. ចូរពន្យល់ខាងក្រោមឱ្យបានត្រឹមត្រូវ ។

- សិក្សា(   ) ..........................................................................................។
- ប្លែក(  )..........................................................................................។
- អនេក(  )...............................................................................................។

២. ចូររកពាក្យបដិសព្ទនឹងពាក្យ " ថ្លៃ  ទំនេរ  " ។

- ថ្លៃ   ≠ ............................។
- ទំនេរ   ≠ ............................។

៣. ចូររកពាក្យវេវចនសព្ទនឹងពាក្យ " សិក្សា  " ។

- សិក្សា.......................................................................................។

៤. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះតាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ  ។

ឆ្នូន   បវរ   បណ្ដាក់   ឆ្លាក់   សិក្សា  ល្អ

ប្រដាប់ប្រដា   យកមក...........   ប្រើប្រាស់ក្នុងថ្នាក់
បន្ទាត់ជ័រលុប   ខ្មៅដៃគូរ   គូសវាស..............
សរសេរអក្សរ ។
សំពៀតក្ដារ..........   យើងប្រើថៃធូន   សំថៃបាន............
កូនខំរៀនសូត្រ   ពុកម៉ែត្រេកអរ   កូនពៅ................
គួរឱ្យសឡាញ់ ។

៥. ចូរគូសភ្ជាប់ប្រអប់ "ក" ទៅប្រអប់ "ខ" ឱ្យជាល្បះមានន័យត្រឹមត្រូវ ។

| ក | ខ |
|---|---|
| - ខ្ញុំខិតខំ | - រៀនសូត្រឱ្យបានពូកែដូចមិត្ត ។ |
| - ថ្ងៃនេះ | - សរសើរពួកយើងគ្រប់ៗគ្នា ។ |
| - យើងទាំងអស់គ្នា | - ចេះស្ដាប់ពេលគ្រូពន្យល់ណែនាំ ។ |
| - សិស្សល្អ | - យើងត្រូវវេនសម្អាតបន្ទប់រៀន ។ |
| - អ្នកគ្រូ | - ត្រូវតែមានអនាម័យស្អាតជានិច្ច ។ |

LIVEWORKSHEETS